ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ: ៤២៦៧/០៥២៥ ... ប.ស្ត/អ៧

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសនិស្សិតស្ម័គ្រចិត្តចូលបំពេញការងារ ឬ ធ្វើកម្មសិក្សា

ក្រសួងបរិស្ថាន មានកិត្តិយសសូមជម្រាបជូនដំណឹងដល់និស្សិត ដែលកំពុងសិក្សានៅតាមបណ្តាមហាវិទ្យាល័យ និងសកលវិទ្យាល័យនានានៅទូទាំងរាជធានីភ្នំពេញជ្រាបថា ដើម្បីផ្តល់ឱកាសដល់និស្សិតក្នុងការរៀនសូត្រដកពិសោធន៍ការងារជាក់ស្តែង ក្រសួងបរិស្ថាន ជ្រើសរើសនិស្សិតស្ម័គ្រចិត្តមកបំពេញការងារ ឬ ធ្វើកម្មសិក្សានៅក្នុងនាយកដ្ឋានព័ត៌មាននិងផ្សព្វផ្សាយបរិស្ថាន នៃអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន ចំនួន ១០(ដប់)នាក់ ស្របទៅតាមកិច្ចសន្យាកំណត់ក្នុងរយៈពេល ៦ខែ(បំពេញការងារ ២វេន/ថ្ងៃ) ឬ ១ឆ្នាំ(បំពេញការងារ ១វេន/ថ្ងៃ)។

<u>ឯកទេសដែលត្រូវជ្រើសរើសមានដូចខាងក្រោម៖</u>

១)ការិយាល័យផ្សព្វផ្សាយព័ត៌មានបរិស្ថាន (០៥នាក់)

| | |
|---|---|
| -ផ្នែកសរសេរខ្លឹមសារព័ត៌មាន | ០២នាក់ |
| - ផ្នែកថតរូប | ០២នាក់ |
| - ផ្នែកកាត់តវីដេអូ | ០១នាក់ |

២)ការិយាល័យព័ត៌មានវិទ្យា (០៤នាក់)

| | |
|---|---|
| - ផ្នែករចនារូប | ០២នាក់ |
| - ផ្នែកគ្រប់គ្រងបណ្តាញសង្គម | ០២នាក់ |

៣) ការិយាល័យរដ្ឋបាល ផែនការនិងហិរញ្ញវត្ថុ (០១នាក់)

| | |
|---|---|
| -ផ្នែករដ្ឋបាល | ០១នាក់ |

<u>ឯកសារភ្ជាប់៖</u>

សូមដាក់ពាក្យដោយភ្ជាប់មកជាមួយនូវ៖

-ប្រវត្តិរូបសង្ខេប(CV)មានបិទរូបថត និង Cover Letter ជាភាសាខ្មែរ

-សញ្ញាបត្របញ្ជាក់ការសិក្សាថតចម្លង ឬ លិខិតបញ្ជាក់ការសិក្សា

-អត្តសញ្ញាណបណ្ណថតចម្លង

<u>ការដាក់ពាក្យ៖</u>

និស្សិតដែលមានចំណាប់អារម្មណ៍ សូមធ្វើការទំនាក់ទំនងចុះឈ្មោះដោយផ្ទាល់មកនាយកដ្ឋានព័ត៌មាននិងផ្សព្វផ្សាយបរិស្ថាន នៃអគ្គនាយកដ្ឋានចំណេះដឹងនិងព័ត៌មានបរិស្ថាន នៃក្រសួងបរិស្ថាន តាមរយៈអ៊ីម៉ែល(nhim.sreipov@moe.gov.kh) និងតេឡេក្រាម(០៩៥ ៥៦៦ ៥០១, ០១៦ ៨៤៥ ៣៤១) យ៉ាងយូរបំផុតត្រឹមថ្ងៃសុក្រ ៤កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី៣០ ខែឧសភា



អគារមរតកតេជោ ដីឡូតិ៍លេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 213 908 / 023 220 369

ឆ្នាំ២០២៥ វេលាម៉ោង ៥ល្ងាច។ ក្រោយបញ្ចប់កម្មសិក្សាដោយជោគជ័យ និស្សិតនឹងទទួលបានវិញ្ញាបនបត្របញ្ជាក់ពីក្រសួងបរិស្ថាន។

<u>បញ្ជាក់</u>៖

-ការទទួលពាក្យស្នើសុំ មានតែតាមរយៈអនឡាញ(Online)ប៉ុណ្ណោះ

-និស្សិតដែលជាប់ជម្រុះបឋមប៉ុណ្ណោះដែលត្រូវអញ្ជើញមកសម្ភាសន៍ផ្ទាល់មាត់។

ថ្ងៃសុក្រ ១៤រោច ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០២៥